ជំពូកទី ៤

មេរៀនទី១

B841

ដំណាកដង្ហើម: អុកស៊ីសែន និងកាបូនឌីអុកស៊ីត

សំនួរគន្លឹះ

តើនៅក្នុងដំណើ រការដកបង្ហើបរបស់មនុស្ស ឧស្ម័នត្រូវបានផ្លា

ស់ប្តូរយ៉ាងដូចម្តេច?

តើអ្នកត្រូវការអ្វី?

ថូកែវពីរ ទៀនដូចគ្នាពី រដើម ចានផើងជ័រតូចពីរ(ឬចានទាប) ឈើគូស កែវពី រ បំពង់ស៊ីយ៉ូ ទឹកក្រូចឆ្មា។

សកម្មភាព

១.សេចក្តីផ្តើម

នៅក្នុងសៀវភៅគីមីថ្នាក់ទី៧ ជំពូកទី៣ មេរៀន "វត្តមាននៃកាបូនឌីអុកស៊ីត"
អ្នកមើលការពិសោធន៍ពីរបៀបបង្ហាញនូវវត្តមានកាបូនឌីអុកស៊ីត
។ ហើយអ្នកនឹងឃើញើផងដែរ ពីវិធីដែលអ្នកអាចធ្វើ និងប្រើទឹក
ក្រូចឆ្មាក្នុងវិធីត្រឹមត្រូវមួយ។

២. ការពិសោធន៍ ១

កត់ត្រានូវការសង្កេតរបស់អ្នក

ក. ដាក់ទៀនចំពាក់កណ្តាលចានផើងដែលមានដំណក់ទៀន
រលាយ។ ដុតទៀនទាំងពីរដើម ហើយគ្រមពីលើទៀនទាំងពីរដើមដោយកែវមួយ។

ខ. យកកែវកញ្ចក់ទាំងពីរចេញ និងបក់ខ្យល់បរិសុទ្ធក្នុងកែវ។ ដុតទៀនទាំងពីរម្តងទៀត។ បន្ទាប់
មកយកកែវមួយ ចេញ ហើយដកដង្ហើមចេញនិងចូលច្រើនដងដោយមិនយកកែវចេញពីមាត់
របស់អ្នក និង គ្របទៀនទាំងពីរម្តងទៀតជាមួយកែវនៅពេលជាមួយគ្នាភ្លាមវិញ។
ចូរប្រៀបធៀបកែវទាំងពីរ។

៣.ការពិសោធន៍ ២

ចាក់ទឹកក្រូចឆ្មាចូលកែវទាំងពីរត្រឹមពាក់កណ្តាលកែវ ក្រឡុកកែវមួយ និងដកដង្ហើមចេញតាមស៊ីយ៉ូ
ក្នុងកែវមួយទៀត។ ប្រៀបធៀបកែវទាំងពីរ។ កត់ត្រានូវការសង្កេតរបស់អ្នក។

៤.ការពិសោធន៍ ៣

ដកដង្ហើមចេញក្នុងកែវកញ្ចក់ទទេដែលត្រជាក់និងស្ងួតជាច្រើនដង ហើយបិតគម្របវិញភ្លាម។
នៅពេលដូចគ្នាដែរ កែវទទេដែលត្រជាក់ និងស្ងួតមួយទៀត ត្រូវបិតគម្របដោយគ្មានការដក
ដង្ហើបចូលវា។ កត់ត្រាទុកនូវការសង្កេតរបស់អ្នក។

លទ្ធផល និងសេចក្តីសន្និដ្ឋាន

កត់ត្រាទុកនូវការសង្កេតរបស់អ្នក និងធ្វើការគូរនូវរូបរន្ធដង្ហើមស្លឹក។ ឆ្លើយនូវសំនួរគន្លឹះ។
មើលតារាងខាងក្រោម

ការស្រាយបញ្ហាក់សម្រាប់គ្រូ

ការពិសោធន៍	*ការសង្កេត*	*ការពន្យល់*
១.ក.ដុតទៀនពីរដើម និងគ្របកែវទាំងពីរដូចគ្នា	ទៀនទាំងពីរនឹងរលត់ បន្តិចក្រោយមក	*ទៀនឆេះ និងត្រូវការអុកស៊ីហ៊ែនពីខ្យល់។ នៅពេលអុកស៊ីហ៊ែនអស់ទៀនរលត់*

១.ខ.ដុតទៀនទាំងពីរ និងគ្របកែវមួយដោយមានខ្យល់ដង្ហើមចេញ និងកែវមួយទៀតជាមួយខ្យល់ធម្មតា	ទៀនក្នុងកែវដែលមានខ្យល់ដង្ហើមចេញរលត់លឿនជាងទៀនមួយទៀត។	*កែវដែលមានខ្យល់ដង្ហើមចេញមានអុកស៊ីហ៊ែនតិចជាង ហើយមានកាបូនឌីអុកស៊ីតច្រើនជាងកែវដែលមានខ្យល់ធម្មតា ដូចនេះ ទៀននៅកែវដកដង្ហើមចេញរលត់លឿនជាង។*
២. ដកដង្ហើមចេញក្នុងទឹកកំបោរថ្លា	សូលុយស្យុងពណ៌នៃកែវដែលគ្មានខ្យល់ដកដង្ហើមចេញ ក្លាយជាពណ៌សដូចដុំពពក កែវដែលដកដង្ហើមចេញក្លាយជាពណ៌អាប់	*ការផ្លាស់ប្តូរពីគ្មានពណ៌ទៅជាពណ៌ស បង្ហាញនូវវត្តមាននៃកាបូនឌីអុកស៊ីត។ខ្យល់ដង្ហើមដកចេញផ្ទុកកាបូនឌីអុកស៊ីតច្រើនជាងខ្យល់ធម្មតានិងផ្តល់នូវការឆាប់កើតមានច្រើនជាង។*
៣.ដកដង្ហើមចេញក្នុងកែវកញ្ចក់ត្រជាក់	ផ្ទៃខាងក្នុងនៃកែវត្រូវចេញចំហាយ និងដំណក់ទឹក លេចឡើង។ កែវដែលដកដង្ហើមចេញមានទឹកច្រើនជាងកែវមួយទៀត។	*ទឹកត្រូវករជាញើសក្នុងផ្ទៃកែវទាំងពីរ។ ដង្ហើមចេញមានទឹកច្រើនជាងដែល កើតចេញពីសួតជាងខ្យល់ធម្មតា។*
តើអ្វីជាចំលើយ របស់អ្នកចំពោះសំណួរគន្លឹះ?		*យើងអាចបង្ហាញនូវការផ្លាស់ប្តូរឧស្ម័នដោយការពិសោធន៍ ដុតទៀនមួយ(អុកស៊ីហ៊ែន និងកាបូនឌីអុកស៊ីត) ទឹកក្រូចឆ្មា(កាបូនឌីអុកស៊ីត) និងកែវ កញ្ចក់ត្រជាក់ (ទឹក)។ ខ្យល់ដង្ហើមចេញផ្ទុកអុកស៊ីហ៊ែនតិចជាងកាបូនឌីអុកស៊ីត និងទឹក។*